ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

**ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋហ្វីលីពីន ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១៧ តាមការអញ្ជើញរបស់ **ឯកឧត្តម អាឡាន ភីទ័រ កាយ៉េតាណូ** (Alan Peter S. Cayetano) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋហ្វីលីពីន។

ក្នុងអំឡុងពេលទស្សនកិច្ចនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន នឹងអញ្ជើញចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម **រ៉ូឌ្រីហ្គោ រ៉ូ ឌូតឺតេ** (Rodrigo Roa Duterte) ប្រធានាធិបតី នៃសាធារណរដ្ឋហ្វីលីពីន។

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន និងឯកឧត្តម អាឡាន ភីទ័រ កាយ៉េតាណូ នឹងអញ្ជើញធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ហ្វីលីពីន លើកទី២ ដែលក្នុងឱកាសនោះ រដ្ឋមន្ត្រីការបរទេសទាំងពីរ នឹងពិភាក្សាលើកិច្ចសហប្រតិបត្តិការមួយចំនួន ដូចជា វិស័យនយោបាយ សេដ្ឋកិច្ច ការពារជាតិ ឧក្រិដ្ឋកម្មឆ្លងដែន និងកិច្ចសហប្រតិបត្តិការសង្គម និងវប្បធម៌។ បញ្ហាបន្ទាន់ក្នុងតំបន់ និងសកលលោក ក៏នឹងត្រូវលើកយកមកពិភាក្សា ផងដែរ ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំនេះ នឹងមានការចុះហត្ថលេខាលើឯកសារ ដូចខាងក្រោម៖

- របាយការណ៍នៃកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ហ្វីលីពីន លើកទី២
- កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការទប់ស្កាត់ការលួច និងជួញដូរខុសច្បាប់នូវសម្បត្តិវប្បធម៌ និង
- អនុស្សរណៈនៃការយោគយល់ រវាងក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការពារជាតិនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ។

ក្នុងឱកាសដែលប្រទេសទាំងពីរ កំពុងប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា និងហ្វីលីពីន ដំណើរទស្សនកិច្ចរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីនៅសាធារណរដ្ឋហ្វីលីពីន នឹងពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ទាំងនៅក្នុងកម្រិតតំបន់ និងអន្តរជាតិ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៧

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh